ធ្វើនៅភ្នំពេញ , ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៣

# សេចក្ដីសំរេច លេខ ២១ សសរ

## ស្ដីពីការបង្កើតគណៈកម្មការសំរាប់ធ្វើការវាយតម្លៃ សេចក្ដីត្រូវការនៃកងទ័ពជាតិកម្ពុជា

* * *

## រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន នៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់សម្ដេចព្រះប្រមុខរដ្ឋ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្ដោះអាសន្ន នៃកម្ពុជា
- យោងតាមកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជានិង រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង អំពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងវិស័យការពារ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៩៣

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការសំរាប់ធ្វើការជាមួយ នាយទាហាន សេនាធិការ នៃបេសកកម្មរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋបារាំងសំរាប់ធ្វើការវាយតម្លៃ សេចក្ដីត្រូវការ នៃកងទ័ពជាតិកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ÷

១- ឯកឧត្ដម ឧត្ដមសេនីយឯក ទៀ បាញ់ អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាន

២- ឯកឧត្ដម ឧត្ដមសេនីយឯក ទា ចំរ៉ាត់ អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាន

៣- ឯកឧត្ដម ឧត្ដមសេនីយឯក កែ គឹមយ៉ាន នាយអគ្គសេនាធិការនៃកងទ័ពជាតិ ជាអនុប្រធាន

៤- លោក ឧត្ដមសេនីយឯក ប៉ាន់ ថៃ នាយកអគ្គសេនាធិការរងនៃកងទ័ពជាតិ ជាសមាជិក

៥- លោក ឧត្ដមសេនីយឯក ប៉ុល សរួន អធិការដ្ឋានក្រសួងការពារជាតិ ជាសមាជិក

៦- លោក ឧត្ដមសេនីយឯក ក្រូច យឿម ខុទ្ទកាល័យក្រសួងការពារជាតិ ជាសមាជិក

៧- លោក ឧត្ដមសេនីយឯក ភួង ស៊ីផាន នាយកដ្ឋានបុគ្គលិក ជាសមាជិក

៨- លោក ឧត្ដមសេនីយឯកបំរុង ស៊ុំ សំណាង នាយកដ្ឋានសម្ភារ ជាសមាជិក

៩- លោក ឧត្ដមសេនីយឯកបំរុង ព្រាប ពាន់ នាយកដ្ឋានផែនការយោធា និង ស៊ីវិល ជាសមាជិក

១០- លោក ឧត្តមសេនីយឯកចំរុង ផាន់ ង៉ុន កងអាកាសចរជាតិកម្ពុជា ជាសមាជិក

១១- លោក ឧត្តមសេនីយឯកចំរុង អ៊ុង សំខាន់ កងនាវាចរជាតិកម្ពុជា ជាសមាជិក

១២- លោក ឧត្តមសេនីយទោ មល់ រឿប ទីប្រឹក្សាសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសមាជិក

១៣- លោក ឧត្តមសេនីយទោ ម៉ឹង សំផន នាយកដ្ឋានថវិកា ជាសមាជិក

១៤- លោក ឧត្តមសេនីយទោ លី ផេង ការិយាល័យទី ១ អគ្គសេនាធិការ ជាសមាជិក

១៥- លោក ឧត្តមសេនីយទោ ហ៊ឹង ឡាង នាយកដ្ឋានទាក់ទងអន្តរជាតិ ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចជួបធ្វើការដោយផ្ទាល់ជាមួយនាយទាហានសេនាធិការ របស់រដ្ឋាភិបាល នៃសាធារណរដ្ឋបារាំងដែលមកបំពេញបេសកកម្ម សំរាប់ធ្វើការវាយតំលៃ សេចក្តីត្រូវការក្នុងកងទ័ពជាតិកម្ពុជា ជួយដល់មន្ត្រីយោធាជាន់ខ្ពស់របស់កម្ពុជា ក្នុងការសិក្សាក្របខ័ណ្ឌទៅ តែបទ និង វិធីរៀបចំរចនាសម្ព័ន្ធនៃកងទ័ពប្រដាប់អាវុធកម្ពុជា ឡើងវិញតាមខ្លឹមសារដែលបានចែងក្នុងកិច្ចព្រមព្រៀង ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គសេនាធិការ ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ។

សហប្រធាន

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * * *